ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

## ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួប
## តំណាងថ្មីនៃអង្គការ World Food Program ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

* * * * * *

នៅព្រឹកថ្ងៃទី**១០** ខែ**តុលា** ឆ្នាំ**២០១៧** វេលាម៉ោង**១០:៣០** នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបលោកស្រី Nancy Walters តំណាងថ្មីរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក(WFP)ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

ជាដំបូង **លោកស្រី** Nancy Walters បានប្រគល់ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** នូវលិខិតរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលបានតែងតាំងលោកស្រីជាប្រធានថ្មីរបស់អង្គការនេះប្រចាំនៅព្រះរាជាចក្រកម្ពុជា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍ចំពោះការតែងតាំង និងការចូលកាន់ការងាររបស់លោកស្រីនៅកម្ពុជា និងបានវាយតម្លៃខ្ពស់ចំពោះបទពិសោធន៍របស់លោកស្រីនៅក្នុងការងាររបស់កម្មវិធីស្បៀងអាហារពិភពលោក។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ចំពោះអង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលបានចូលមកជួយកម្ពុជាតាំងពីឆ្នាំ១៩៧៩ គឺក្នុងពេលដែលកម្ពុជាកំពុងតែជួបការលំបាកខ្លាំងខាងផ្នែកស្បៀងអាហារ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើន និងលទ្ធផលប្រកបដោយផ្លែផ្កា ក្នុងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ រវាងរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័នផ្សេងៗរបស់កម្ពុជា ជាមួយនឹងអង្គការកម្មវិធីស្បៀងអាហារពិភពលោក។

លោកស្រី Nancy Walters បានរំលឹកឡើងវិញអំពីប្រវត្តិដ៏យូរលង់នៃកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងអង្គការកម្មវិធីស្បៀងអាហារពិភពលោក ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ហើយនិងជោគជ័យនៃកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរនេះ ។ លោកស្រី ក៏បានសម្តែងនូវការចាប់អារម្មណ៍ ចំពោះការរីកចម្រើនដែលសម្រេចបាននៅកម្ពុជា។ លោកស្រីបានអះអាងអំពីភាពរីករាយរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ក្នុងការបន្តកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភដល់ប្រទេសកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងអំពីការពេញចិត្តរបស់ឯកឧត្តម ចំពោះជោគជ័យនៃការអនុវត្តកម្មវិធីសំខាន់ៗមួយចំនួនរបស់កម្មវិធីស្បៀងអាហារពិភពលោក ជាអាទិ៍ កម្មវិធីផ្តល់ស្បៀងអាហារនៅសាលារៀន ដែលតាមរយៈកម្មវិធីនោះ អង្គការកម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ចំណីអាហារដល់

កុមារនៅតាមសាលារៀន ដោយផ្តោតគោលដៅជាសំខាន់ទៅលើកុមារក្រីក្រនៅតាមជនបទ។ **ឯកឧត្តម** បានវាយតម្លៃថា កម្មវិធីនេះបានរួមចំណែកដ៏សំខាន់ក្នុងការបង្កលក្ខណៈអនុគ្រោះអោយកុមារក្រីក្រ បានចូលរៀនដូចកុមារផ្សេងៗទៀត ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការរួមវិភាគទានដ៏សកម្មរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ក្នុងការជួយកម្ពុជាសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពិសេសគឺគោលដៅទី១ ស្តីអំពីការកាត់បន្ថយភាពក្រីក្រ ហើយនិងគោលដៅទី២ ស្តីអំពីការលុបបំបាត់ទាំងស្រុងនូវភាពអត់ឃ្លាន។ **ឯកឧត្តម** បានឆ្លៀតឱកាសនេះ ជម្រាបជូនលោកស្រី Nancy Walters អំពីការខិតខំនិងការរីកចម្រើនគួរអោយកត់សម្គាល់ ដែលរាជរដ្ឋាភិបាលសម្រេចបាន ក្នុងការអនុវត្តគោលដៅទាំងពីរនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ចំពោះការជួយឧបត្ថម្ភ ហើយនិងកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក លើការផ្គត់ផ្គង់ម្ហូបអាហារ ( Nutrition ) ពិសេសគឺ កិច្ចសហប្រតិបត្តិការរបស់WFP ជាមួយនឹងក្រុមប្រឹក្សាសម្រាប់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទរបស់កម្ពុជា ដើម្បីជួយអោយកម្ពុជាអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពស្តីពីសន្តិសុខស្បៀងនិងការផ្គត់ផ្គង់ម្ហូបអាហារ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ផងដែរចំពោះកិច្ចសហប្រតិបត្តិការរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ជាមួយអង្គការកាកបាទក្រហមកម្ពុជា ក្នុងការពង្រឹងសមត្ថភាពរបស់កម្ពុជាសម្រាប់ធ្វើការឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់។

លោកស្រី Nancy Walters បានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដោយត្រួសៗ អំពីជោគជ័យនៃសកម្មភាពរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោកនៅកម្ពុជា ពិសេសគឺកិច្ចសហប្រតិបត្តិការ និងការជួយដល់កម្ពុជាលើផ្នែកសន្តិសុខស្បៀងអាហារ ការផ្គត់ផ្គង់ម្ហូបអាហារ និងការជួយដល់កុមារកម្ពុជា តាមរយៈកម្មវិធីផ្គត់ផ្គង់ម្ហូបអាហារនៅតាមសាលារៀន។

**លោកស្រី** ក៏បានអះអាងជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការប្តេជ្ញាចិត្តរបស់កម្មវិធីស្បៀងអាហារពិភពលោក ក្នុងការបន្តជួយឧបត្ថម្ភនិងផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អជាមួយកម្ពុជាបន្តទៀត ហើយបានថ្លែងអំណរគុណចំពោះក្រសួងការបរទេស ដែលជានិច្ចជាកាលតែងតែផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អចំពោះWorld Food Program។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអះអាងជូនលោកស្រី អំពីការត្រៀមខ្លួនរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយបង្កលក្ខណៈងាយស្រួលសំរាប់ការបំពេញការងាររបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ក៏ដូចជាជួយសម្របសម្រួលចំពោះកិច្ចសហប្រតិបត្តិការរវាងអង្គការកម្មវិធីស្បៀងអាហារពិភពលោក ជាមួយស្ថាប័នដែលពាក់ព័ន្ធផ្សេងៗរបស់កម្ពុជា។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧